00231761

D99/3/23

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ០២)

ចំពោះមុខ:

ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ប៉ែន ពេជ្រសាលី
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ១៤ តុលា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 10 / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

---

**សាធារណៈ:**

## សេចក្តីសម្រេចលើពាក្យសុំរបស់លោក អៀង សារី សុំដកអ្នកដែលមិនមែនជាភាគីនៃរឿងក្តី

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**

កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN
Philippe CANNONE

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("**អវតក**") បានទទួលពាក្យសុំរបស់សហមេធាវីការពារក្តីលោក អៀង សារី "សុំដកគុណវុឌ្ឍិសាស្ត្រាចារ្យ **អានតូនីអូ កាសេស៊ី** និងសមាជិកមួយចំនួននៃក្រុមប្រឹក្សានិពន្ធ និងគណៈកម្មាធិការនិពន្ធ នៃទិនានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ ពីការដាក់សារណាជាលាយលក្ខណ៍អក្សររបស់ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ស្តីពីបញ្ហាសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច"" ដែលបានដាក់នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ ("ពាក្យសុំ")។

២. សហព្រះរាជអាជ្ញាបានដាក់សេចក្តីសន្និដ្ឋានតបចំពោះពាក្យសុំនេះ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨។

៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា លោក អៀង សារី មិនមែនជាភាគីនៃរឿងក្តីលេខ ០០១/១៨-៧-២០០៧-អវតក-កសចស ដែលរឿងក្តីនេះ ពាក់ព័ន្ធករណីជនត្រូវចោទ "ឌុច" តែម្នាក់ឯង ប៉ុណ្ណោះ។[១]

៤. នៅក្នុងពាក្យសុំ ដែលធ្វើឡើងដោយអនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង (*សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី*) និង វិធាន ៣៤ នៃវិធានផ្ទៃក្នុង (ការដកខ្លួន និងបណ្តឹងជិតចិត្តចំពោះចៅក្រម) សហមេធាវីការពារក្តីលោក អៀង សារី ហាក់ដូចជាចាប់យកសិទ្ធិចូលរួមដោយផ្ទាល់ នៅក្នុងរឿងក្តីមួយផ្សេងទៀត។

៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុង "សេចក្តីសម្រេចរបស់ខ្លួនលើសំណើរបស់លោក អៀង សារី សុំដាក់សារណាស្តីពីការអនុវត្តទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះយល់ឃើញថា ជនត្រូវចោទ **អៀង សារី** មិនមានសិទ្ធិអន្តរាគមន៍នៅក្នុងរឿងក្តីប្រឆាំងចំពោះជនត្រូវចោទ **ឌុច** ស្តីពីបញ្ហានៃការអនុវត្តន៍ទ្រឹស្តីសហកម្មឧក្រិដ្ឋកម្មរួមឡើយ។

៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ជនត្រូវចោទ អៀង សារី គ្មានផលប្រយោជន៍ខាងផ្លូវច្បាប់ ក្នុងការដាក់ពាក្យសុំនេះឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

បដិសេធចោលពាក្យសុំនេះ។

ភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER

**ប្រាក់ គឹមសាន**

[១] ដីកាបំបែករឿងក្តី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ D18។